ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-May-2012, 12:43
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២**

**ម៉ោង ០៩:២៧ នាទី**

**សវនាការលើកទី៦២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រីនណា

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

លោកស្រី ឡូរ៍ ដេសហ្វកស៍
*(Ms.Laure DESFORGES)*

លោក ប៉ាស្កាល់ អូប៊ីង
*(Mr. Pascal AUBOUIN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:២៧:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុកនៅថ្ងៃនេះ ជាការចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-487 ដែលអង្គជំនុំជម្រះគ្រោងធ្វើសវនាការ ក្នុងរយៈពេលបួនថ្ងៃនៅក្នុងសប្តាហ៍នេះ។

ក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលត្រូវអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ ស្ថានភាពវត្តមាន និងអវត្តមានរបស់ភាគី ដែលចូលរួមនៅក្នុងសវនាការថ្ងៃនេះមានដូចខាងក្រោម៖ ការិយាល័យសហព្រះរាជអាជ្ញា មានវត្តមានគ្រប់ចំនួន។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានវត្តមាន។ ហើយក៏មានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ឈ្មោះលោកស្រី ឡូរ៍ ដេសហ្វកស៍ ដែលលោកស្រី ឡូរ៍ ដេសហ្វកស៍ មិនទាន់បានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះនៅឡើយទេ។ ក្រុមមេធាវីការពារក្តី នួន ជា មានវត្តមាន។ ក្រុមមេធាវីការពារជនជាប់ចោទ ខៀវ សំផន មានវត្តមាន។ ក្រុមមេធាវីការពារលោក អៀង សារី មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាន។ ជនជាប់ចោទ លោក ខៀវ សំផន មានវត្តមាន។ ជនជាប់ចោទ លោក អៀង សារី អវត្តមាន។ សាក្សី TCW-487 ដែលអង្គជំនុំជម្រះបានកោះហៅ មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ដើម្បីចូលសាលសវនាការ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយ។ សូមអរគុណលោកប្រធាន។

[០៩:២៩:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមានបញ្ហាអីទៅ លោកមេធាវី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ មានចំណុចពីរ ដែលខ្ញុំចង់សូមជម្រាបលោកប្រធាន ហើយសូមគោរពផងដែរ ដល់អង្គសវនាការទាំងមូល លោក លោកស្រីចៅក្រម។ ចំណុចទីមួយ ពាក់ព័ន្ធទៅនឹងការអន្តរាគមន៍ពាក់ព័ន្ធទៅសាក្សី TCW-487 នេះ មេធាវីនាំមុខស្នើសុំប្រគល់ភារកិច្ចនេះជូនលោកមេធាវី បាណាបេ ណេគ្វី ហើយនិងលោកមេធាវី ឡោ ជុនធី។ ហើយចំណុចមួយទៀត ដូចក្រឡាបញ្ជីបានរាយការណ៍ ជូនលោកប្រធាន គឺមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្មីមួយ ដែលខ្ញុំបាទមិនទាន់បានស្នើសុំឲ្យមានការទទួលស្គាល់ពីលោក លោកស្រីចៅក្រម។ មេធាវីថ្មីនោះ គឺមានឈ្មោះ ឡូរ៍ ដេសហ្វកស៍ ជាមេធាវីបារាំង នៅក្នុងក្រុមមេធាវីគ្មានព្រំដែនរបស់បារាំង ហើយដែលត្រូវបាន ទទួលឲ្យចូលនៅក្នុងគណៈមេធាវីកម្ពុជារួចហើយ ហើយដែលត្រូវបានធ្វើសម្បថ នៅចំពោះសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជារួចហើយ នៅឆ្នាំ២០១០។ ដូច្នេះ សុំមេធាវី-- សុំលោកប្រធាន មេត្តាទទួលស្គាល់មេធាវី ឡូរ៍ ដេសហ្វកស៍ នេះ ដើម្បីឲ្យលោកស្រីមានសិទ្ធិពេញលេញ នៅក្នុងការបំពេញការតំណាងកូនក្តីរបស់ខ្លួន នៅចំពោះមុខអង្គជំនុំជម្រះនេះ។ សូមលោកប្រធានជ្រាប។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញក្រោកឈរ លោកស្រីមេធាវី ឡូរ៍ ដេសហ្វកស៍!

[០៩:៣១:១៩]

លោកស្រី ឡូរ៍ ដេសហ្វកស៍ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកស្រីជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ។ អនុលោមតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិ តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែរ។ សូមលោកស្រីអង្គុយចុះ!

នៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដោយមានការអវត្តមានជនជាប់ចោទ អៀង សារី ដោយសារមានមូលហេតុបញ្ហាសុខភាព ដើម្បីជាក់លើបញ្ហា អង្គជំនុំជម្រះចាត់ក្រឡាបញ្ជី ឌុច ផារី អានន្ទូវរបាយការណ៍របស់គ្រូពេទ្យ ដែលផ្នែកខាងសង្គ្រោះបន្ទាន់ដែលកំពុងតែព្យាបាលជំងឺដល់លោក អៀង សារី ដើម្បីមានមូលដ្ឋានក្នុងការពិចារណារបស់ភាគីដែលពាក់ព័ន្ធ។

សូមអញ្ជើញលោក ឌុច ផារី!

**ក្រឡាបញ្ជី៖**

គោរពជូន ប្រធានអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។

តាមរយៈការិយាល័យរដ្ឋបាលនៃពេទ្យមិត្តភាពខ្មែរ-សូវៀត ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក។

កម្មវត្ថុ របាយការណ៍សុខភាពរបស់លោក អៀង សារី។

[០៩:៣៣:១៣]

កាលពីព្រឹកថ្ងៃទី១៧ ឧសភា ២០១២ លោក អៀង សារី ត្រូវបានបញ្ជូនមកសម្រាកព្យាបាលនៅផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រោមរោគសញ្ញាក្អកជាប់ ពិបាកដកដង្ហើម និងវិលមុខ។ រយៈពេលនៃព្យាបាល និងតាមដានបញ្ជាក់ថា លោក អៀង សារី មានរោគវិនិច្ឆ័យរលាកទងសួត ស្រួចស្រាល់ បន្ថែមទៅលើរោគដែលលោកមានស្រាប់ពីពេលមុន ជំងឺបេះដូង និងសរសៃឈាម។ ស្ថានភាពជំងឺមានសភាពធូរស្រាលក្រោមការព្យាបាលកន្លងមក។ ផ្នែកផ្លូវដង្ហើមនឹងអាចចេញពីមន្ទីរពេទ្យនៅព្រឹក ថ្ងៃអង្គារ ទី២២ ឧសភា ២០១២ ខាងមុខនេះ។ ក្រោយពីចេញពីមន្ទីរពេទ្យអ្នកជំងឺត្រូវសម្រាកចំនួនពីរថ្ងៃ ដោយយោងលើស្ថានភាពជំងឺ។

ដោយយោងតាមកម្មវត្ថុដូចបានជម្រាបជូនខាងលើ សូមលោកប្រធាន អ.វ.ត.ក មេត្តាជ្រាប។

ភ្នំពេញ, ថ្ងៃទី២០ ឧសភា ២០១២

ប្រធានផ្នែកសង្គ្រោះបន្ទាន់ វេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា

សូមអរគុណ លោកប្រធាន។

[០៩:៣៤:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។

បាទ ឥឡូវនេះ បន្ទាប់ពីបានស្តាប់នូវរបាយការណ៍របស់គ្រូពេទ្យព្យាបាល បាននិងកំពុងព្យាបាលសុខភាពលោក អៀង សារី។

[០៩:៣៥:០០]

អង្គជំនុំជម្រះសូមសួរទៅភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ ថាតើភាគីមានមតិយោបល់អ្វីដែរលើបញ្ហាករណីអវត្តមានលោក អៀង សារី ដោយសារមូលហេតុសុខភាព ហើយបាននិងកំពុងសម្រាកនៅព្យាបាល-- អឺ! ព្យាបាលនៅមន្ទីរពេទ្យដូចនេះ។

ប្រសិនបើមានសូមអញ្ជើញ!

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម ព្រមទាំងប្រិយមិត្តទាំងអស់ដែលនៅក្នុង និងនៅក្រៅសវនាការ។ ជាការគួរឲ្យសោកស្ដាយដែរ ដែលលោក អៀង សារី មានជំងឺ។ ការពិតទៅគាត់មិនបានលើក-- លះបង់សិទ្ធិចូលរួមនៅក្នុងសវនាការ ឬក៏បោះបង់ចោលសិទ្ធិចូលនៅក្នុងកិច្ចដំណើរការនីតិវិធីនេះទេ។

[០៩:៣៥:៥៧]

ដូច្នេះហើយតាមជំហររបស់មេធាវី គឺថា កិច្ចដំណើរការនីតិវិធីមិនគួរបន្តទៅមុខឡើយរហូតដល់ពេលដែលគាត់បានជាសះស្បើយពីជំងឺ ឬក៏មួយនៅពេលដែលគាត់បានលះបង់សិទ្ធិចូលរួម។ នេះគឺជាគោលជំហរ នេះគឺជាបទដ្ឋានរបស់អន្តរជាតិ ហើយសូម្បីតែតុលាការអន្តរជាតិនានា ក៏គោរពទៅតាមបទដ្ឋាន ទៅតាមគោលការណ៍មួយនេះដែរ។ តាមគោលការណ៍នេះ គឺលោក អៀង សារី ត្រូវជួយទៅដល់ខាងមេធាវីការពារក្ដី ប៉ុន្តែយើងខ្ញុំមិនទទួលបានការណែនាំ ឬក៏ជួយនៅពេលនេះឡើយ។ ដូច្នេះប្រសិនបើលោក អៀង សារី មិនមានវត្តមានទេ គាត់មិនអាចជួយខ្ញុំបានទេ។ ដូច្នេះគោលជំហររបស់យើង គឺថាយើងគួរតែរង់ចាំដល់ពេលលោក អៀង សារី គាត់មានសុខភាពល្អប្រសើរឡើងវិញ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ នេះគឺពិតជាស្ថានភាពថ្មីមួយ សវនាការចុងក្រោយនោះ កាលពីថ្ងៃព្រហស្បតិ៍ លោក អៀង សារី បានចាកចេញពីសវនាការ ហើយគាត់បានយល់ព្រមឲ្យមានការបន្តដំណើរការនីតិវិធីសួរសំណួរសាក្សី គឺលោក ពាន យាន។ ដូច្នេះវា-- ក្នុងករណីនេះ គឺថាមានវិធានមួយ គឺវិធាន៨១(១) និយាយថា ជនជាប់ចោទត្រូវតែទទួលការវិនិច្ឆ័យនៅចំពោះមុខ-- នៅចំពោះវត្តមានរបស់គាត់ ហើយនិងវិធាន៨១(៥) ក៏មាននិយាយដែរ។ ដូច្នេះការលំបាកនៅទីនេះ គឺថាគាត់មិនមានលទ្ធភាពនៅក្នុងការផ្ដល់ការណែនាំដល់មេធាវីរបស់គាត់។

ដូច្នេះនៅក្នុងលក្ខខណ្ឌនេះ ខ្ញុំគិតថា មេធាវីការពារក្តីត្រូវតែនិយាយបញ្ជាក់ថា តើមានការយល់ព្រមពីគាត់ឬក៏អត់ ក្នុងការបន្តសវនាការនេះ?

[០៩:៣៨:១៧]

បញ្ហាចោទឡើងនោះ គឺថាយើងមិនអាចដឹងទេថា តើនៅពេលណាដែលលោក អៀង សារី អាចមានវត្តមានបាននោះ? គាត់មកស្អែក ឬក៏ខានស្អែកអីយើងមិនដឹងទេ។ ដូច្នេះយើងខ្ញុំយល់ថា ដើម្បីឲ្យមានការដំណើរការបន្តល្អ នីតិវិធីល្អនោះ យើងខ្ញុំសង្ឃឹមថា នៅថ្ងៃស្អែកនេះលោក អៀង សារី គាត់នឹងអាចមានលទ្ធភាពក្នុងការចូលរួមនៅក្នុងសវនាការបានពីបន្ទប់នៅខាងក្រោមសវនាការនេះ។ នេះជាគោលជំហររបស់សហព្រះរាជអាជ្ញា លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ដោយបានពាក់ព័ន្ធទៅនឹងការមិនអាចចូលរួមដោយមូលហេតុជំងឺនេះ ខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏មិនមានអ្វីជំទាស់ទៅនឹងអ្វីដែលបានលើកឡើងដោយមេធាវីការពារក្តី ក៏ដូចជាខាងព្រះរាជអាជ្ញាក្តី គឺដោយសារថា យើងគោរពទៅលើសិទ្ធិរបស់គាត់ដូចមានចែងនៅក្នុងវិធាន៨១ នៃវិធានផ្ទៃក្នុងនេះ។ យើងខ្ញុំមិនមានបំណងនៅក្នុងការបង្ខំឲ្យគាត់-- បង្ខំថាឲ្យត្រូវតែមានសវនាការដោយគ្មានវត្តមានរបស់គាត់នោះទេ។ ដូច្នេះ ក្នុងករណីដែលគាត់មានជំងឺដោយមិនអាចចូលរួមបែបនេះ យើងអាច-- មេធាវីសូមស្នើថា មិនអាចគោរពតាមការស្នើរបស់ខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

ក្នុងនាមកូនក្តីលោក នួន ជា ខ្ញុំមេធាវីសូមគាំទ្រនូវការសុំផ្អាកបណ្តោះអាសន្នរបស់លោកកាណាវាស មេធាវីរបស់ អៀង សារី ពីព្រោះតាមមើលឯកសារសាក្សីនៅថ្ងៃនេះ ជាសាក្សីមួយដែលមានការពាក់ព័ន្ធចំពោះករណីលោក អៀង សារី ច្រើន។ ហេតុនេះមិន-- មេធាវីរបស់លោក អៀង សារី មិនទាន់បានទីប្រឹក្សាលោក អៀង សារី នៅធ្វើជា-- ដើម្បីផ្តល់យោបល់នឹងទីប្រឹក្សារបស់គាត់ គាត់មិន

អាចធ្វើបាន។ ខ្ញុំសូមគាំទ្រនូវគំនិតលោក កាណាវាស។ សូមអរគុណ។

[០៩:៤១:១១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី។

សូមអញ្ជើញលោកស្រីមេធាវីការពារ-- អន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោក លោកស្រីចៅក្រម។ យើងខ្ញុំសូមគាំទ្រយ៉ាងស្រុងទៅនឹងសំណើរបស់មេធាវីការពារក្តី អៀង សារី។ វានេះគឺជាសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការមានវត្តមាននៅពេលដែលគេវិនិច្ឆ័យគាត់។ ដូច្នេះ យើងត្រូវតែគោរពគោលការណ៍នេះ។ យើងត្រូវតែធានានីតិវិធីចំពោះភាគីទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទសូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:៣៣]

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី អៀង សារី គឺថាមានបញ្ហាពីរដែលខ្ញុំចង់ឱ្យលោកផ្តល់យោបល់មុនពេលដែលលោកប្រធានបានធ្វើការសម្រេចទៅលើបញ្ហាទីមួយ។ ទីមួយ គឺបញ្ហាអំពីការផ្តល់នូវស្ថានភាព សុខភាពរបស់កូនក្តីរបស់លោកជូនទៅដល់សាធារណៈ។ ខ្ញុំគិតថាប្រហែលជាលោកមិនមានការជំទាស់ទេ ប្រសិនបើយើងផ្តល់ព័ត៌មានទៅដល់សាធារណជន ប៉ុន្តែចំពោះអនាគតលោកអាចនឹងមានការជំទាស់ចំពោះការផ្តល់ព័ត៌មានទៅដល់សាធារណជន។ នេះជាសំណួរទីមួយ។

សំណួរទីពីរ គឺយើងចង់បញ្ជាក់ច្បាស់ថា លោកមិនមានការលំបាកនៅក្នុងការទាក់ទងជាមួយកូនក្តីរបស់លោកនៅពេលដែលកូនក្តីរបស់លោកស្នាក់នៅមន្ទីរពេទ្យ។ តើលោកអាចជម្រាបយើងបានដែរឬទេ? សូមអរគុណ។

[០៩:៤៤:៤៩]

**លោក ម៉ៃខល កាណាវ៉ាស៖**

ចំពោះសំណួរទីមួយ គឺថាវាជាការដែលល្អដែលយើងបានផ្តល់ព័ត៌មានអំពីបញ្ហាសុខភាព។ គឺថាយើងមិនគួរឲ្យអ្នកណាម្នាក់មិនដឹងអំពីបញ្ហានេះឡើយ ប៉ុន្តែខ្ញុំគិតថា ខ្ញុំនឹងប្រឹក្សាជាមួយលោក អៀង សារី ថាតើយើងត្រូវផ្តល់សំណួរយ៉ាងម៉េចដែរ? ប៉ុន្តែខ្ញុំគិតថា ចំពោះបញ្ហាទីមួយគាត់មិនជំទាស់ទៅលើការផ្តល់ព័ត៌មាននោះឡើយ ដើម្បីឲ្យមានតម្លាភាព។ ចំពោះបញ្ហាទីពីរ គឺយើងមិនអាចទទួល ឬក៏យើងមិនអាចជួបជាមួយកូនក្តីរបស់យើងបានទេ ព្រោះថាខាងមន្ទីរពេទ្យ ខាងពេទ្យប្រាប់ថាយើងមិនអាចទៅជួបគាត់បានឡើយនៅពេលនេះ។ ហើយកាលពីពេលកន្លងមកក៏យើងមិនព្យាយាម ដើម្បីចូលទៅជួបជាមួយគាត់នោះដែរ។ ដូច្នេះ ខ្ញុំគិតថាយើងនឹងព្យាយាមទៅជួបគាត់នៅថ្ងៃនេះ។ ដូច្នេះអានេះគឺជាអ្វីដែលខ្ញុំអាចជម្រាបជូនលោកស្រីចៅក្រមបាន។ សូមអរគុណ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ការពិតហើយ គឺយើងត្រូវទុកសិទ្ធិឲ្យខាងមន្ទីរពេទ្យក្នុងការសម្រេចឲ្យបានច្បាស់លាស់ថា តើលោកអាចជួបគាត់បានឬក៏អត់? ដូច្នេះ ចំពោះបញ្ហានេះគឺថា លោកអាចទុកឲ្យខាងអង្គជំនុំជម្រះមេត្តាដោះស្រាយទៅលើបញ្ហានេះ។ សូមលោក កាណាវ៉ាស ជ្រាបជាព័ត៌មាន។

[០៩:៤៦:១២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ក្រោយពីបានឃើញនិងបានអានទូវខ្លឹមសារនៃរបាយការណ៍របស់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលបាននិងកំពុងពិនិត្យព្យាបាលសុខភាពរបស់ជនជាប់ចោទឈ្មោះ អៀង សារី ហើយនិងបានបញ្ជាក់ច្បាស់ថា លោក អៀង សារី នឹងអាចចេញពីមន្ទីរពេទ្យបានលុះត្រាតែថ្ងៃ-- រហូតដល់ថ្ងៃស្អែកទើបអាចចេញពីមន្ទីរពេទ្យបាន។ ដោយលោក អៀង សារី កន្លងមកនេះគាត់បានមានបញ្ហាសុខភាព ហើយគាត់បានទទួលការសង្គ្រោះបន្ទាន់ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២។ ទីពីរ គឺក្រោយពីបានស្តាប់នូវមតិយោបល់របស់ភាគីដែលពាក់ព័ន្ធ ជាពិសេសគឺមេធាវីការពារក្តីរបស់លោក អៀង សារី បានបង្ហាញជំហរច្បាស់លាស់អំពីការដែលខ្លួនគាត់លើកយោបល់ថា មិនគប្បីដំណើរការសវនាការដោយគ្មានវត្តមានរបស់កូនក្តីរបស់គាត់ទេ ដោយសារគោរពតាមគោលការណ៍ច្បាប់អន្តរជាតិផង ហើយនិងស្ថានភាពនៃអាការៈជំងឺ ដែលកន្លងមកគាត់មិនដែលបានពិគ្រោះ ប្រឹក្សាយោបល់ជាមួយនឹងកូនក្តីរបស់

គាត់ផង។

[០៩:៤៧:៣២]

ហើយភាគីដែលពាក់ព័ន្ធដទៃទៀតក៏សូម-- ជាទូទៅឃើញថា គាំទ្រនៅលើមតិយោបល់នេះ។ ហើយដោយផ្អែកទៅលើវិធាន៨១(៥)-- វិធាន៨១ ជាទូទៅ ហើយជាពិសេស ហើយនិងដោយឡែកពាក់ព័ន្ធនឹងចំណុចទីប្រាំនោះ អង្គជំនុំជម្រះសម្រេចថា កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ និងថ្ងៃស្អែកមិនអាចដំណើរការបានទេ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ហើយនិងសវនាការនឹងលើកទៅធ្វើនៅថ្ងៃពុធ ទី២៣ ខែឧសភា ឆ្នាំ២០១២។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនផងដែរ កិច្ចដំណើរការសវនាការដែលអង្គជំនុំជម្រះគ្រោងទៅធ្វើនៅថ្ងៃពុធនេះ គឺមានកិច្ចការពីរដោយឡែកពីគ្នា ប៉ុន្តែពាក់ព័ន្ធគ្នា។ គឺចាប់ផ្តើមដំបូងអង្គជំនុំជម្រះនឹងដំណើរការស្តាប់នូវមតិយោបល់របស់គ្រូពេទ្យ ដែលបាននិងកំពុងព្យាបាលលោក អៀង សារី បច្ចុប្បន្ននេះ ដើម្បីឲ្យគាត់ឲ្យផ្តល់នូវដំបូន្មានពាក់ព័ន្ធទៅនឹងកិច្ចដំណើរការសវនាការនៅខាងមុខ ជាពិសេសចុងសប្តាហ៍នេះ ថាតើលទ្ធភាពរបស់លោក អៀង សារី ដែលក្រោយពីចេញពីមន្ទីរពេទ្យនោះ ថាតើគាត់អាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបានដែរឬទេ?

[០៩:៤៩:០៣]

ហើយបើសិនបើគាត់ចូលរួមបាន តើអាចចូលរួមបានតាមវិធីណា? ដោយផ្ទាល់ ឬក៏តាមរយៈពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍? នេះជាបញ្ហា។ ហើយប្រសិនបើមតិនោះយោបល់នោះវាវិជ្ជមាន បានន័យថាអាចដំណើរការទៅបាននោះ អង្គជំនុំជម្រះនឹងចាប់ផ្តើមដំណើរការសវនាការអង្គសេចក្តីតែម្តងក្រោយពេលដំណើរការស្តាប់នូវមតិយោបល់របស់គ្រូពេទ្យ ដែលព្យាបាលជនជាប់ចោទ។

ក្នុងករណីអវិជ្ជមាន គឺអង្គជំនុំជម្រះនឹងជម្រាបជូនភាគី និងសាធារណជនជាក់ច្បាស់អំពីបញ្ហានោះនៅពេលក្រោយ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនទៅដល់សាធារណជន ហើយនិងភាគីផងដែរថា ដោយមានបញ្ហាដូច្នេះនៅក្នុងសប្តាហ៍នេះ ប្រសិនបើអាចធ្វើទៅបាន នៅក្នុងចុងសប្តាហ៍នេះ អង្គជំនុំជម្រះនឹងខិតខំប្រឹងប្រែងបន្ត ពិនិត្យលទ្ធភាពក្នុងការបន្តធ្វើសក្ខី-- ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ថ្ងៃសុក្រផងដែរ ដោយសារដើម្បីន័យនៅក្នុងការជំរុញពន្លឿនកិច្ចដំណើរការសវនាការរបស់យើង។

បាទ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយ

សវនាការលើកទៅបន្តធ្វើនៅថ្ងៃពុធ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ដូចបានជម្រាបរួចហើយ។ ហើយដោយឡែកសាក្សី TCW-487 សូមឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីបញ្ជូនគាត់ត្រឡប់ទៅវិញ ហើយនិងឲ្យអញ្ជើញគាត់ឲ្យមានវត្តមាននៅ អ.វ.ត.ក នៅថ្ងៃ-- នៅព្រឹកថ្ងៃពុធ ទី២៣ ខែឧសភា ឆ្នាំ២០១២ ដើម្បីជាការបម្រុងលទ្ធភាពនៃវិជ្ជមាននៅក្នុងដំណើរការសវនាការដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនោះ។

[០៩:៥១:១៧]

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ទាំងពីរនាក់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃពុធ ទី២៣ ខែឧសភា ឆ្នាំ២០១២។ ដោយឡែកចំពោះលោក អៀង សារី ក្រោយពីចេញមន្ទីរពេទ្យគឺអង្គជំនុំជម្រះមិនទាន់តម្រូវឲ្យគាត់មកទីនេះទេ គឺចាំស្តាប់នូវមតិយោបល់របស់គ្រូពេទ្យជាមុនសិនថាតើវិធីក្នុងការឲ្យគាត់ចូលរួមតាមវិធីណា? តាមមធ្យោបាយនោះ គឺទៅតាម-- អង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចទៅតាមស្ថានភាពជាក់ស្តែង។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ០៩:៥២ នាទី)*